១២-លោក **ស៊ឹម យ៉ន** គ្រូបង្រៀនពុទ្ធិកបឋមសិក្សា

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា និង អភិបាលខេត្តបន្ទាយមានជ័យ ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

195-196

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៤៧ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

* * * * * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម ០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី២៣ ខែ មីនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## ស ំ រ េ ច

**មាត្រា ១ :** ត្រូវបានតែងតាំងលោកស្រី ***តឿង សគុណា*** ជានាយិកា នៃវិទ្យាស្ថាន បច្ចេកវិទ្យាកម្ពុជា របស់ក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- ឯកសារ- កាលប្បវត្តិ

## ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ០៤ ភិសារ

# សេចក្តីសំរេច

## ស្តីពីការបង្កើតគណៈប្រតិភូកម្ពុជា សំរាប់ធ្វើការចរចាជាមួយគណៈប្រតិភូរបស់អង្គការយូណេស្កូ លើការចុះឈ្មោះប្រាសាទព្រះវិហារក្នុងបញ្ជីបេតិកភណ្ឌពិភពលោក

*************

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើ ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- តាមសំណើរបស់តំណាងអង្គការយូណេស្កូ (UNESCO) ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា
- តាមសភាពការណ៍ចាំបាច់

## សំរេច

**ប្រការ១:** បង្កើតគណៈប្រតិភូកម្ពុជាសំរាប់ធ្វើការចរចាជាមួយគណៈប្រតិភូរបស់អង្គការយូណេស្កូលើការចុះឈ្មោះប្រាសាទព្រះវិហារក្នុងបញ្ជីបេតិកភណ្ឌពិភពលោក ដែលមានសមាសភាពដូចខាងក្រោមៈ

| | | | |
|---|---|---|---|
| ១- ឯកឧត្តម | **សុខ អាន** | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | ប្រធាន |
| ២- ឯកឧត្តម | **នី យ៉ាត** | រដ្ឋលេខាធិការក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ | អនុប្រធាន |
| ៣- ឯកឧត្តម | **វ៉ា គឹមហុង** | ប្រធានគណៈកម្មាធិការកិច្ចការព្រំដែនកម្ពុជាថៃ | អនុប្រធាន |
| ៤- ឯកឧត្តម | **ទី នាឃី** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៥- ឯកឧត្តម | **ជុច តៀន** | អនុរដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | អនុប្រធាន |

| | | | | |
|---|---|---|---|---|
| ៦- ឯកឧត្តម | **សេំ** | **ឫទ្ធីត់** | អគ្គនាយករងអាជ្ញាធរអប្សរានិងជាសមាជិកក្រុមប្រឹក្សាប្រតិបត្តិអង្គការ យូណេស្កូ | សមាជិក |
| ៧- លោកជំទាវ | **តាន់** | **ធាវី** | អគ្គលេខាធិការគណៈកម្មការជាតិកម្ពុជាសំរាប់យូណេស្កូ | សមាជិកា |
| ៨- លោក | **បុទ** | **ម៉ុនឃួន** | ប្រធាននាយកដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | លេខាធិការ |

**ប្រការ២:** គណៈប្រតិភូកម្ពុជាមានភារកិច្ចដូចតទៅ :

- សិក្សាស្រាវជ្រាវ ប្រមូលលិខិតបទដ្ឋានគតិយុត្តិគ្រប់ជំនាន់ ផែនទីនានា និងឯកសារពាក់ពន្ធ័ជុំវិញប្រាសាទព្រះវិហារ ដើម្បីធ្វើជាទឡ្ហីករណ៍ក្នុងការចរចាជាមួយអង្គការយូណេស្កូ (UNESCO) ។
- ប្រជុំដើម្បីប្រមូលផ្តុំនូវយោបល់សំខាន់ៗជាគន្លឹះ សំរាប់បំរើការក្នុងការងារចរចាជាក់ស្តែងជាមួយអង្គការយូណេស្កូ(UNESCO) ។
- បូកសរុបខ្លឹមសារនៃការត្រៀមរៀបចំឯកសារ និងខ្លឹមសារចរចាដើម្បីរាយការណ៍សុំយោបល់ណែនាំដ៏ខ្ពង់ខ្ពស់ពីប្រមុខរាជរដ្ឋាភិបាល ។
- ក្រោយពេលចរចាចប់ ត្រូវរាយការណ៍បូកសរុបជូនប្រមុខរាជរដ្ឋាភិបាល ។

**ប្រការ៣:** សមាជិកគណៈប្រតិភូកម្ពុជាត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានគណៈប្រតិភូ ។

**ប្រការ៤:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី, រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, រដ្ឋមន្ត្រី, រដ្ឋលេខាធិការ, នៃក្រសួងស្ថាប័នពាក់ពន្ធ័ និងសាមីខ្លួនដែលមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសំរេចនេះតាមភារកិច្ចអោយមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ មករា ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

<u>កន្លែងទទួល:</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ៤
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ០៥ ស.ស.រ

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីសម្របសម្រួល វាយតម្លៃ និងត្រួតពិនិត្យ លើវត្ថុបុរាណសិល្បៈខ្មែរ ដែលក្រុមហ៊ុន TOEI ជប៉ុន ខ្ចីយកទៅតាំងពិព័រណ៍ នៅប្រទេសជប៉ុន រយៈពេល ១៤ ខែ ចាប់ពីខែ មិថុនា ឆ្នាំ ២០០៥ ដល់ខែ កក្កដា ឆ្នាំ ២០០៦ និង សារមន្ទីរសិល្បៈនិងមហោស្រពពិព័រណ៍ នៃ សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ ខ្ចីយកទៅតាំងពិព័រណ៍នៅទីក្រុងបោន សាធារណៈរដ្ឋសហព័ន្ធអាល្លឺម៉ង់ រយៈពេល ៦ ខែ ឆ្នាំ ២០០៦-២០០៧

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស /រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ
- យោងតាមតម្រូវការចាំបាច់ នៃការងារ

# **សំ រេ ច**

**ប្រការ ១:** ត្រូវបានបង្កើតគណៈកម្មការអន្តរក្រសួងមួយ ដើម្បីសម្របសម្រួល វាយតម្លៃ និងត្រួតពិនិត្យ លើវត្ថុបុរាណសិល្បៈខ្មែរ ដែលក្រុមហ៊ុន TOEI ជប៉ុន ខ្ចីយកទៅតាំងពិពណ៌នៅប្រទេសជប៉ុន រយៈពេល ១៤ ខែ ចាប់ពីខែ មិថុនា ឆ្នាំ ២០០៥ ដល់ខែ កក្កដា ឆ្នាំ ២០០៦ និង សារមន្ទីរសិល្បៈ និងមហោស្រពពិពណ៌នៃសាធារណរដ្ឋសហពន្ធ័អាល្លឺម៉ង់ ខ្ចីយកទៅតាំងពិពណ៌នៅទីក្រុងបោន សារធារណៈរដ្ឋសហពន្ធ័អាល្លឺម៉ង់ រយៈពេល ៦ ខែ ឆ្នាំ ២០០៦-២០០៧ ដែលមានសមាសភាព ដូចតទៅ :

| | | |
|---|---|---|
| ១- សម្តេចព្រះរាម **នរោត្តម បុប្ផាទេវី** | រដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ | ជាព្រះប្រធាន |
| ២- ឯកឧត្តម **ព្រំ សុខា** | រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៣- ឯកឧត្តម **ថោង ខុន** | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ៤- ឯកឧត្តម **យឹម សារីន** | ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រី និងជាអនុរដ្ឋលេខាធិការ ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ | សមាជិក |
| ៥- ឯកឧត្តម **នឹម ចាន់ដារ៉ា** | អនុរដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ៦- ឯកឧត្តម **ទី តាយី** | អនុរដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ៧- ឯកឧត្តម **សេង លីមនៅ** | អនុរដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៨- ឯកឧត្តម **ជុច គឿន** | អនុរដ្ឋលេខាធិការ ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ | សមាជិក |
| ៩- ឯកឧត្តម បណ្ឌិត **ប៉ែន ដារេត** | ទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិកអចិន្ត្រៃយ៍ និងជា អគ្គលេខាធិការគណៈកម្មការ |
| ១០- ឯកឧត្តម **ស៊ុម សួន** | ទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រី ទទួលបន្ទុកការងារទេសចរណ៍ | សមាជិក |
| ១១- លោកជំទាវ **តាន់ តានី** | អគ្គលេខាធិការគណៈកម្មការជាតិយូណេស្កូ (UNESCO) | សមាជិក |
| ១២- ឯកឧត្តម បណ្ឌិត **ក្រាញ់ ទេយ៉ាលាភី តូនី** | សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ នៃរាជរដ្ឋាភិបាលកម្ពុជា | សមាជិក |
| ១៣- ឯកឧត្តម **សេ៎ ប៊ូរ៉ាត** | អគ្គនាយករងអាជ្ញាធរអប្សរា ទទួលបន្ទុកការងារ រមណីយដ្ឋាននិងបុរាណវិទ្យា | សមាជិក |
| ១៤- ឯកឧត្តម **នុយ គឿន** | សាកលវិទ្យាធិការ សកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ | សមាជិក |
| ១៥- លោក **ពេជ កែវ** | អគ្គនាយករងបច្ចេកទេស ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ១៦- លោក **អ៊ឹង ចន** | ប្រធាននាយកដ្ឋានបិតិកភណ្ឌវប្បធម៌ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | សមាជិក |
| ១៧- លោក **ឃុន សារ៉េន** | ប្រធាននាយកដ្ឋាន សារមន្ទីរ នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ១៨- លោក **ខឹម ចិសិដ្ឋ** | ប្រធាននាយកដ្ឋានអប់រំ វប្បធម៌សង្គមកិច្ច ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ១៩- លោក **គង់ អួក** | ប្រធាននាយកដ្ឋាន សង្គមស៊ីវិល អង្គការក្រៅរដ្ឋាភិបាល និងសិទ្ធិមនុស្ស ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |

**ប្រការ ២:** គណៈកម្មការនេះមានភារៈកិច្ចធ្វើការទំនាក់ទំនងនិងក្រសួងពាក់ពន្ធ័នានា និងក្រុមហ៊ុន TOEI នៃប្រទេសជប៉ុន និងសារៈមន្ទីរសិល្បៈ និងមហោស្រពពិពណ៌នៃសាធារណរដ្ឋសហពន្ធ័អាល្លឺម៉ង់ដើម្បីសម្របសម្រួល វាយតម្លៃ និងត្រួតពិនិត្យលើវត្ថុបុរាណសិល្បៈខ្មែរ សំរាប់ទៅតាំងពិពណ៌នៅប្រទេសជប៉ុន រយៈពេល ១៤ ខែ ចាប់ពីខែ មិថុនា ឆ្នាំ ២០០៥ ដល់ខែ កក្កដា ឆ្នាំ ២០០៦ និងនៅ សារមន្ទីរសិល្បៈ និងមហោស្រពពិពណ៌ នៅទីក្រុងបោន សាធារណៈរដ្ឋសហពន្ធ័អាល្លឺម៉ង់ រយៈពេល ៦ ខែ ឆ្នាំ ២០០៦-២០០៧ ។

**ប្រការ ៣:** គណៈកម្មការនេះមានអគ្គលេខាធិការដ្ឋាន នៅទីស្តីការគណៈរដ្ឋមន្ត្រី ។

**ប្រការ ៤:** នាយកដ្ឋានសង្គមស៊ីវិល អង្គការក្រៅរដ្ឋាភិបាល និងសិទ្ធិមនុស្ស និងនាយកដ្ឋាន អប់រំ វប្បធម៌និងសង្គមកិច្ច នៃទីស្តីការគណៈរដ្ឋមន្ត្រី ជាសេនាធិការ នៃអគ្គលេខាធិការ ។

**ប្រការ ៥:** សេចក្តីសំរេចនេះត្រូវជំនួសលើសេចក្តីសំរេចរបស់រាជរដ្ឋាភិបាល លេខ ៥៣ សសរ ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០០៣ ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីវាយតម្លៃនិងត្រួតពិនិត្យវត្ថុបុរាណសិល្បៈខ្មែរ ដែលក្រុមហ៊ុន TOEI ជប៉ុន ខ្ចីយកទៅតាំងពិពណ៌នៅប្រទេសជប៉ុន រយៈពេលមួយឆ្នាំ ចាប់ពីខែ កញ្ញា ឆ្នាំ ២០០៤ ។

**ប្រការ ៦:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាជ្ញាធរអប្សរា ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មការ ដែលបានរាយនាមក្នុង ប្រការ ១ ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ-ថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ៦
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ០៦ អនក

## សេចក្តីសំរេច
## ស្តីពី
## ការប្រគល់សិទ្ធិ

### រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៧២ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ
- បានឃើញ អនុក្រឹត្យលេខ ៩១ អនក្រ.បក ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល
- យោងតាមសំណើរបស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

### សំរេច

**ប្រការ ១.-** ត្រូវបានដកសិទ្ធិ ឯកឧត្តម **ប្រាក់ សុខុន** ពីអ្នកសំរបសំរួលគំរោង ស្តីពី ការពង្រឹងសមត្ថភាពផ្នែកសេដ្ឋកិច្ច និង រដ្ឋបាលសាធារណៈ ។

**ប្រការ ២.-** ត្រូវបានប្រគល់សិទ្ធិជូនឯកឧត្តម **ង៉ោ ហុងលី** អគ្គលេខាធិការ នៃក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ជា អ្នកសំរបសំរួលគំរោង ស្តីពី ការពង្រឹងសមត្ថភាពផ្នែកសេដ្ឋកិច្ច និង រដ្ឋបាលសាធារណៈ។

/K

**ប្រការ ៣.-** រាល់បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសំរេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៤.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ ក្រុមប្រឹក្សា អាជ្ញាធរជាតិ គ្រប់ក្រសួង-ស្ថាប័ន និងឯកឧត្តម ដែលមានក្នុងប្រការ ១ និងប្រការ ២ ត្រូវអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែកុម្ភៈ ឆ្នាំ ២០០៤*

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

*កន្លែងទទួល :*

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ៤*
- *កាលប្បវត្តិ-ឯកសារ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា
លេខ :.០.១.....អយក.សរណន

# សារាចរណែនាំ

## ស្តីពី

## ការប្រលងបញ្ចប់ភូមិសិក្សាផ្នែកចំណេះទូទៅ បំពេញវិជ្ជាសាធារណៈ និងឯកជន

យោង :- ប្រកាសលេខ ២១១ អយក.ប្រក របស់ក្រសួងអប់រំ យុវជន និងកីឡាចុះថ្ងៃទី ២៧ មករា ២០០០ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃការប្រលងសញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិ

- ប្រកាសលេខ ៧៨ អយក.ប្រក របស់ក្រសួងអប់រំ យុវជន និងកីឡាចុះថ្ងៃទី ២២ មករា ២០០២ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃការប្រលងសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ
- សេចក្តីណែនាំលេខ ៤០២៥ អយក.មចទ ចុះថ្ងៃទី ២៤ ធ្នូ ២០០៣ ស្តីពីការរៀបចំប្រលងឆមាស នៅគ្រឹះស្ថានមធ្យមសិក្សាចំណេះទូទៅសំរាប់ឆ្នាំសិក្សា ២០០៣_២០០៤

នៅឆ្នាំសិក្សា ២០០៣_២០០៤នេះ ពិន្ទុសរុបនៃការប្រលងសញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិនៅតែរក្សាយក ពិន្ទុប្រចាំឆ្នាំ បូកនឹងពិន្ទុប្រលងថ្នាក់ជាតិ ។ ដោយឡែកការប្រលងសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ ត្រូវយក ពិន្ទុប្រចាំឆ្នាំកំនែតំរូវ បូកនឹងពិន្ទុប្រលងថ្នាក់ជាតិ ។

ដើម្បីអោយការប្រលងថ្នាក់ជាតិ និងការរៀបចំប្រលងឆមាសទី១ និងទី២តាមសាលារៀន មានលក្ខណៈល្អ ប្រសើរ ក្រសួងសូមធ្វើការណែនាំដូចតទៅ :

**I. កាលបរិច្ឆេទប្រលង :**

**I.1.** ប្រលងសញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិ :

- កាលបរិច្ឆេទ : ថ្ងៃទី ១០ កក្កដា ២០០៤
- កាលបរិច្ឆេទនៃការទទួលពាក្យសុំប្រលង : ថ្ងៃទី ១៦ កុម្ភៈ ២០០៤ ដល់ថ្ងៃទី ១៣ មីនា ២០០៤

**I.2.** ប្រលងសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ :

- កាលបរិច្ឆេទ : ថ្ងៃទី ០៦ សីហា ២០០៤
- កាលបរិច្ឆេទនៃការទទួលពាក្យសុំប្រលង : ថ្ងៃទី ១៦ កុម្ភៈ ២០០៤ ដល់ថ្ងៃទី ១៣ មីនា ២០០៤

**II. បេក្ខភាពសិស្ស និងសំណុំលិខិតដាក់ពាក្យប្រលង :**

**II.1.** សំណុំលិខិតដាក់ពាក្យសុំប្រលងរបស់បេក្ខជន ត្រូវសរសេរដោយដៃបេក្ខជនផ្ទាល់ (គំរូជូនភ្ជាប់) បិទតែម ៣០០រៀល និងមានភ្ជាប់បង្កាន់ដៃបង់សិទ្ធិសុំប្រលងដូចខាងក្រោម :

- បេក្ខជនប្រលងសញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិ បង់ថ្លៃសិទ្ធិប្រលង ១០០០រៀល ។
- បេក្ខជនប្រលងសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ បង់ថ្លៃសិទ្ធិប្រលង ១៥០០រៀល ។

II.2. បេក្ខភាព :

ក. បេក្ខភាពប្រលងសញ្ញាប័ត្រ មធ្យមសិក្សាបឋមភូមិ :

* សិស្សសាលារៀនចំនេះទូទៅសាធារណៈ និងឯកជនដែល ÷

- មានអាយុ១៤ឆ្នាំយ៉ាងតិច។
- បានរៀនចប់មធ្យមសិក្សាបឋមភូមិ គ្រប់កំរិតថ្នាក់។
- បានរៀនចប់កម្មវិធីសិក្សាថ្នាក់ទី៩។
- បានគោរពត្រឹមត្រូវតាមបទបញ្ជាផ្ទៃក្នុង សំរាប់គ្រឹះស្ថានមធ្យមសិក្សា។
- បានត្រូវវាយតំលៃផ្នែកសីលធម៌ប្រចាំឆ្នាំ ចាប់ពីមធ្យមឡើងទៅ។

អាចដាក់ពាក្យសុំប្រលងសញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិ នៅតាមគ្រឹះស្ថានសិក្សារបស់ខ្លួនបាន។

ខ. បេក្ខភាពប្រលងសញ្ញាប័ត្រ មធ្យមសិក្សាទុតិយភូមិ :

* សិស្សសាលារៀនចំនេះទូទៅសាធារណៈ និងឯកជនដែល ÷

- មានសញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិ។
- បានរៀននៅមធ្យមសិក្សាទុតិយភូមិគ្រប់កំរិតថ្នាក់។
- បានរៀនចប់កម្មវិធីថ្នាក់ទី១២ ។
- បានគោរពត្រឹមត្រូវតាមបទបញ្ជាផ្ទៃក្នុង សំរាប់គ្រឹះស្ថានមធ្យមសិក្សា។
- បានត្រូវវាយតំលៃផ្នែកសីលធម៌ប្រចាំឆ្នាំចាប់ពីមធ្យមឡើងទៅ។

អាចដាក់ពាក្យសុំប្រលងសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ នៅតាមគ្រឹះស្ថានសិក្សារបស់ខ្លួនបាន។

+ លើកលែងតែ :

- សិស្សដែលឈប់ដោយមានច្បាប់ ចាប់ពី៤៥ដងឡើងទៅ។
- សិស្សដែលឈប់ឥតច្បាប់ និងមានច្បាប់ ចាប់ពី៣០ដងឡើងទៅ។
- សិស្សដែលឈប់ឥតច្បាប់ ចាប់ពី២០ដងឡើងទៅ។
- សិស្សដែលគ្មានមធ្យមភាគពិន្ទុឆមាសទី១ រឺឆមាសទី២។

* អតីតបេក្ខជនដែលបានប្រលងធ្លាក់សញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិ អាចដាក់ពាក្យសុំប្រលងសញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិនៅតាមមន្ទីរអប់រំ យុវជន និងកីឡាខេត្ត-ក្រុង ដែលសាមីខ្លួនបានសុំប្រលងពីមុន រឺអាចដាក់ពាក្យសុំប្រលង នៅតាមមន្ទីរអប់រំ យុវជន និងកីឡាខេត្ត-ក្រុងផ្សេងទៀត ដោយគ្រាន់តែធ្វើសេចក្តីបញ្ជាក់ពីការប្រលងធ្លាក់លើពាក្យសុំប្រលង ពីមន្ទីរអប់រំយុវជន និងកីឡាខេត្ត-ក្រុង ដែលសាមីខ្លួនបានប្រលងធ្លាក់ពីមុន។

* អតីតបេក្ខជនដែលបានប្រលងធ្លាក់សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ អាចដាក់ពាក្យសុំប្រលងសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ នៅតាមមន្ទីរអប់រំ យុវជន និងកីឡាខេត្ត-ក្រុង ដែលសាមីខ្លួនបានសុំប្រលងពីមុន រឺនៅនាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ នៃក្រសួងអប់រំ យុវជន និងកីឡា។

** កំនត់សំគាល់ :

* ចំនួនអវត្តមានត្រូវគិតចាប់ពីបវេសនកាល រហូតដល់ថ្ងៃទី ២៥ មិថុនា ២០០៤ សំរាប់សិស្សថ្នាក់ទី ១២ និងថ្ងៃទី ០៣ មិថុនា ២០០៤ សំរាប់សិស្សថ្នាក់ទី ៩ ។

II.3. បញ្ជីបេក្ខភាព_បញ្ជីរាយនាមសិស្ស ប្រលងឆមាសលើកទី១_ទី២ និងតារាងស្រង់ពិន្ទុប្រចាំឆ្នាំ :

នៅដើមឆ្នាំសិក្សា នាយកវិទ្យាល័យត្រូវផ្ញើបញ្ជីឈ្មោះសិស្សថ្នាក់ទី១២ ទៅមន្ទីរអប់រំ យុវជន និងកីឡា។ មន្ទីរអប់រំ យុវជន និងកីឡា ត្រូវវាយបញ្ចូលឈ្មោះសិស្សថ្នាក់ទី១២ដែលទទួលបានពីវិទ្យាល័យនីមួយៗទៅក្នុងកុំព្យូទ័រ។ ក្រោយពីពិនិត្យផ្ទៀងផ្ទាត់ និងកែតម្រូវរួចមន្ទីរត្រូវ ÷

_បោះពុម្ពជាលើកទី១ នូវបញ្ជីរាយនាមសិស្សតាមលំដាប់អក្ខរក្រម តាមបន្ទប់ និងតារាងស្រង់ពិន្ទុប្រលងឆមាសទី១ តាមបន្ទប់ (ចំនួនបេក្ខជនក្នុងមួយបន្ទប់ត្រូវយកតាមការកំនត់របស់វិទ្យាល័យនីមួយៗ) បញ្ជូនទៅវិទ្យាល័យនីមួយៗ យ៉ាងហោចណាស់២សប្តាហ៍មុនថ្ងៃប្រលងឆមាស។ វិទ្យាល័យនីមួយៗ ក្រោយពីទទួលបានបញ្ជីរាយនាមសិស្សថ្នាក់ទី១២តាមបន្ទប់ ត្រូវថតចំលងបិទផ្សាយបញ្ជីទាំងនោះអោយសិស្សមើល ដើម្បីពិនិត្យ ឈ្មោះ ថ្ងៃខែឆ្នាំកំនើត ក្រែងមានការខុសឆ្គង។ ក្រោយពីទទួលបានព័ត៌មានត្រលប់មកវិញ នាយកត្រូវផ្ញើបញ្ជីកែតម្រូវ (តាមគំរូលេខ០១ជូនភ្ជាប់) ទៅមន្ទីរអប់រំ យុវជន និងកីឡាវិញ។

_ក្រោយពីបានទទួលបញ្ជីកែតម្រូវពីវិទ្យាល័យ មន្ទីរអប់រំ យុវជន និងកីឡា ត្រូវកែតម្រូវទិន្នន័យក្នុងកុំព្យូទ័រ រួចបោះពុម្ពផ្ញើទៅសាលាវិញ។

<u>សំគាល់:</u> ក្រដាស ទឹកខ្មៅ សំរាប់បោះពុម្ពបញ្ជីឈ្មោះ និងតារាងស្រង់ពិន្ទុ.....ជាបន្ទុករបស់សាលា ដោយប្រើប្រាស់ថវិកា PAP3 ក្នុងខ្ទង់សំភារៈមូលដ្ឋាន។

_បោះពុម្ពជាលើកទី២នូវបញ្ជីបេក្ខភាព តារាងស្រង់ពិន្ទុប្រចាំឆ្នាំ ផ្ញើទៅវិទ្យាល័យនីមួយៗ ក្រោយពេលប្រលងឆមាសលើកទី១ពីរសប្តាហ៍ ដើម្បីអោយវិទ្យាល័យនីមួយៗ ធ្វើការផ្ទៀងផ្ទាត់។ ក្នុងការផ្ទៀងផ្ទាត់នោះ វិទ្យាល័យនីមួយៗ ត្រូវយកវិញ្ញាបនបត្របណ្ដោះអាសន្នមធ្យមសិក្សាបឋមភូមិធ្វើជាគោល ផ្ទៀងផ្ទាត់ជាមួយសលាកបត្រឯកត្តជន និងបញ្ជីបេក្ខភាព។ បើពិនិត្យទៅមានខុសឆ្គង វិទ្យាល័យនីមួយៗ ត្រូវកែដោយប៊ិចក្រហមនៅលើបញ្ជីបេក្ខភាព និងតារាងស្រង់ពិន្ទុប្រចាំឆ្នាំ ព្រមទាំងធ្វើបញ្ជីរាយនាមឈ្មោះសិស្ស ដែលត្រូវកែតម្រូវ (តាមគំរូ លេខ០២ជូនភ្ជាប់) ផ្ញើមកការិយាល័យប្រលង នៃនាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ តាមរយៈមន្ទីរអប់រំ យុវជន និងកីឡា ខេត្ត_ក្រុងដោយភ្ជាប់ជាមួយនូវពាក្យសុំប្រលងរបស់បេក្ខជនផង អោយបានមុនថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៤។

* លោកនាយក_នាយិកាសាលា :

- ត្រូវពិនិត្យសំនុំលិខិតដាក់ពាក្យសុំប្រលងរបស់សិស្ស ដោយផ្ទៀងផ្ទាត់អោយបានត្រឹមត្រូវនូវ ឈ្មោះថ្ងៃ.ខែ..ឆ្នាំកំនើត ទីកន្លែងកំនើត ឈ្មោះឪពុកម្ដាយរបស់សិស្ស ដែលសរសេរក្នុងពាក្យសុំប្រលង និងសលាកបត្រឯកត្តជន និងអត្តសញ្ញាណប័ណ្ណ។ ពាក្យសុំប្រលង និងសលាកបត្រឯកត្តជនរបស់សិស្ស ត្រូវសរសេរអោយច្បាស់។ ត្រូវណែនាំសិស្សអោយរក្សាទុករូបថត ដែលបានបិទលើសលាកបត្រឯកត្តជន ដើម្បីងាយស្រួលក្នុងការសុំធ្វើវិញ្ញាបនបត្របណ្ដោះអាសន្ន នៅពេលប្រលងជាប់។
- ត្រូវណែនាំអោយសិស្សសរសេរសំនុំលិខិតដាក់ពាក្យសុំប្រលងដោយខ្លួនឯង ចៀសវាងប្រមូលយកទៅអោយគ្រូទទួលបន្ទុកថ្នាក់ រឺមិត្តភក្តិ រឺអ្នកដទៃសរសេរជំនួស។
- ត្រូវចុះហត្ថលេខា និងបោះត្រាលើសលាកបត្រពិន្ទុប្រចាំឆ្នាំ របស់សិស្សថ្នាក់ទី៩ (បេក្ខជនម្នាក់ៗបំពេញជា២ច្បាប់) ដែលសរសេរបំពេញដោយផ្ទាល់ដៃសិស្ស ចៀសវាងការកោសលុប រឺសរសេរត្រួត។ ចំពោះសិស្សថ្នាក់ទី១២ ពុំមានសលាកបត្រពិន្ទុប្រចាំឆ្នាំទេ។ បន្ទាប់ពីឈប់ទទួលពាក្យសុំប្រលង ត្រូវរាប់ចំនួនសិស្សដាក់ពាក្យសុំប្រលងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ និងចំនួនសិស្សដាក់ពាក្យសុំប្រលងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ផ្ញើមកមន្ទីរអប់រំ យុវជន និងកីឡាខេត្ត_ក្រុងដោយ ÷

- ១ច្បាប់សំរាប់មន្ទីរអប់រំ យុវជន និងកីឡា ដើម្បីវាយឈ្មោះសិស្សបញ្ចូល Diskette តាមវិទ្យាល័យនីមួយៗ រួចមន្ទីរអប់រំយុវជន និងកីឡាខេត្ត_ក្រុងផ្ញើ Diskette នោះ មកនាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ អោយបានមុនថ្ងៃទី ០១ មេសា ២០០៤។
- ១ច្បាប់ សំរាប់ក្រសួង (នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ ) ដោយភ្ជាប់វិញ្ញាបនប័ត្របណ្តោះអាសន្ន មធ្យមសិក្សាបឋមភូមិ សម័យប្រលងត្រឹមឆ្នាំ ២០០១ រឺមុនឆ្នាំ ២០០១ អោយបានមុនថ្ងៃទី ០១ មេសា ២០០៤ ដើម្បីក្រសួងផ្ទៀងផ្ទាត់ភេតុភាព។

**III. ការកំនត់មណ្ឌលប្រលង :**

កន្លងមក គ្រឹះស្ថានសិក្សាមួយចំនួននៅតាមខេត្ត_ក្រុងដែលត្រូវបានយកធ្វើជាមណ្ឌលប្រលង នាយក_នាយិកាសាលាពុំទាន់បានរៀបចំអោយអស់លទ្ធភាព ដើម្បីធានាអោយដំនើរការប្រលងប្រព្រឹត្តទៅបានល្អប្រសើរនៅឡើយ។ ដូចនេះ លោក_លោកស្រីប្រធានមន្ទីរអប់រំ យុវជន និងកីឡា ត្រូវជ្រើសរើសយកគ្រឹះស្ថានណា ដែលមានជំបូលពុំធ្លុះធ្លាយ មានរបងព័ទ្ធជុំវិញ មានមាត់ច្រកចេញ ចូល មានសោរចាក់ត្រឹមត្រូវ សំរាប់ធ្វើជាមណ្ឌលប្រលង និងណែនាំ អោយនាយក_នាយិកាសាលា ដែលសាលារបស់ខ្លួនត្រូវបានជ្រើសរើសធ្វើជាមណ្ឌលប្រលង សំអាតទីធ្លារ អគារ បន្ទប់អនាម័យអោយហើយស្រេចមុនដំនើរការប្រលង។ បន្ទប់ប្រលងនីមួយៗ ត្រូវរៀបចំអោយមានតុ ជើងម៉ាមាំទាំ ដើម្បីអោយបេក្ខជនងាយស្រួលក្នុងការសរសេរកិច្ចការ។ បើតុ ជើងម៉ាពុំមាំទាំ ត្រូវជួសជុល រឺរកជើងម៉ាថ្មីមកប្តូរ។ បន្ទប់ប្រលងនីមួយៗត្រូវអោយមានតុ២៥យ៉ាងតិច (តុសំរាប់សិស្សអង្គុយរៀនធម្មតា១រឺ២នាក់) និង១៣តុយ៉ាងតិច (តុសំរាប់សិស្សអង្គុយរៀនធម្មតាបួននាក់)។

មណ្ឌលប្រលងនីមួយៗ ត្រូវមានប្រដាប់បំពងសំលេង ដែលអាចប្រើប្រាស់បាន នៅពេលដំនើរការប្រលង។ សាលាដែលត្រូវយកធ្វើមណ្ឌលប្រលងត្រូវរក្សាទុកបុគ្គលិក ២រឺ៣នាក់ ទៅតាមទំហំមណ្ឌលប្រលង។ បុគ្គលិករក្សាទុកនេះត្រូវជ្រើសរើសអ្នកដែលចេះប្រើប្រាស់ និងរៀបចំប្រដាប់បំពងសំលេង ហើយឈ្លាសវៃក្នុងការដោះស្រាយកង្វះខាតសំភារៈផ្សេងៗ។ ហាមដាច់ខាត ការលក់ដូរនៅ ក្នុងមណ្ឌលប្រលង ក្នុងរយៈពេលដំនើរការ ការងារប្រលង។ ត្រូវផ្ញើកំនត់មណ្ឌលប្រលង ទៅក្រសួង (នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ ) អោយបានមុនថ្ងៃទី ០១ មេសា ២០០៤។

**IV. សំនើប្រធានវិញ្ញាសាប្រលង :**

លោកគ្រូ អ្នកគ្រូបង្រៀនថ្នាក់ទី១២ និងទី៩ ត្រូវផ្ញើសំនើប្រធានវិញ្ញាសាប្រលង ១វិញ្ញាសាក្នុងមួយមុខវិជ្ជាសំរាប់អ្នកបង្រៀនម្នាក់ ដោយភ្ជាប់អត្រាកំនែមកជាមួយផង ដើម្បីជាទុនសំរាប់ក្រសួងពិចារណា និងជ្រើសរើស។ លោកគ្រូ អ្នកគ្រូដែលជាអ្នកស្នើប្រធានវិញ្ញាសា ត្រូវរក្សាការសំងាត់ និងតំលៃមុខវិជ្ជារបស់ខ្លួន ដោយស្មារតីទទួលខុសត្រូវខ្ពស់ចំពោះមុខក្រសួង ។

ផ្នែកខាងលើនៃសំនើប្រធានវិញ្ញាសានីមួយៗ ត្រូវសរសេរតាមគំរូជូនភ្ជាប់។ សំនើប្រធានវិញ្ញាសានីមួយៗត្រូវដាក់ក្នុងស្រោមសំងាត់ ដោយបញ្ជាក់មុខវិជ្ជាលើស្រោមនោះផង។

នាយក_នាយិកាសាលា ត្រូវប្រមូលស្រោមសំនើប្រធានវិញ្ញាសាទាំងអស់ ដាក់ក្នុងស្រោមសំងាត់រួម រួចផ្ញើទៅនាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ តាមរយៈមន្ទីរអប់រំ យុវជន និងកីឡាខេត្ត_ក្រុងអោយបានមុនថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០០៤។

*ចំពោះវិញ្ញាសាដែលត្រូវផ្ញើសំនើមានដូចតទៅ :*

ក. <u>សំរាប់ការប្រលងសញ្ញាប័ត្រមធ្យមសិក្សា ទុតិយភូមិ</u> :

១_ ភាសាខ្មែរ ............... រយៈពេល ១២០នាទី ត្រូវបានពិន្ទុ ពី ០ ដល់ ១០០។

២_ គណិតវិទ្យា .............. រយៈពេល ១៥០នាទី ត្រូវបានពិន្ទុ ពី ០ ដល់ ១២៥។
៣_ រូបវិទ្យា .............. រយៈពេល ៩០នាទី ត្រូវបានពិន្ទុ ពី ០ ដល់ ៧៥។
៤_ គីមី .............. រយៈពេល ៦០នាទី ត្រូវបានពិន្ទុ ពី ០ ដល់ ៥០។
៥_ ជីវវិទ្យា .............. រយៈពេល ៦០នាទី ត្រូវបានពិន្ទុ ពី ០ ដល់ ៥០។
៦_ ផែនដីវិទ្យា .............. រយៈពេល ៣០នាទី ត្រូវបានពិន្ទុ ពី ០ ដល់ ២៥។
៧_ ប្រវត្តិវិទ្យា .............. រយៈពេល ៤៥នាទី ត្រូវបានពិន្ទុ ពី ០ ដល់ ៣៧។
៨_ ភូមិវិទ្យា .............. រយៈពេល ៤៥នាទី ត្រូវបានពិន្ទុ ពី ០ ដល់ ៣៨។
៩_ សីលធម៌_ពលរដ្ឋវិជ្ជា ....... រយៈពេល ៦០នាទី ត្រូវបានពិន្ទុ ពី ០ ដល់ ៥០។
១០_ សំនួរទំរង់បិទ ............ រយៈពេល ៦០នាទី ត្រូវបានពិន្ទុ ពី ០ ដល់ ៥០។

ខ. <u>សំរាប់ការប្រលងសញ្ញាបត្រមធ្យមសិក្សា បឋមភូមិ</u> :

១_ ភាសាខ្មែរ .............. រយៈពេល ១២០នាទី ត្រូវបានពិន្ទុ ពី ០ ដល់ ១០០។
២_ គណិតវិទ្យា .............. រយៈពេល ១២០នាទី ត្រូវបានពិន្ទុ ពី ០ ដល់ ១០០។
៣_ រូបវិទ្យា .............. រយៈពេល ៤០នាទី ត្រូវបានពិន្ទុ ពី ០ ដល់ ៣០។
៤_ គីមី .............. រយៈពេល ៤០នាទី ត្រូវបានពិន្ទុ ពី ០ ដល់ ២៨។
៥_ ជីវវិទ្យា .............. រយៈពេល ៤០នាទី ត្រូវបានពិន្ទុ ពី ០ ដល់ ២៨។
៦_ ផែនដីវិទ្យា .............. រយៈពេល ៤០នាទី ត្រូវបានពិន្ទុ ពី ០ ដល់ ២៨។
៧_ ប្រវត្តិវិទ្យា .............. រយៈពេល ៤០នាទី ត្រូវបានពិន្ទុ ពី ០ ដល់ ២៨។
៨_ ភូមិវិទ្យា .............. រយៈពេល ៤០នាទី ត្រូវបានពិន្ទុ ពី ០ ដល់ ២៨។
៩_ សីលធម៌_ពលរដ្ឋវិជ្ជា ....... រយៈពេល ៤០នាទី ត្រូវបានពិន្ទុ ពី ០ ដល់ ៣០។
១០_ ភាសាបរទេស ........... រយៈពេល ៤៥នាទី ត្រូវបានពិន្ទុ ពី ០ ដល់ ៥០។

លោក_លោកស្រីប្រធានមន្ទីរអប់រំយុវជន និងកីឡា ត្រូវផ្សព្វផ្សាយការណែនាំនេះដល់គ្រប់គ្រឹះស្ថានមធ្យមសិក្សា ដើម្បីអោយការអនុវត្តមានប្រសិទ្ធភាពខ្ពស់។

ភ្នំពេញ ថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០០៤
រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា
រដ្ឋលេខាធិការ

អ៊ឹម សិទ្ធី

**ចំលងជូន** :
_ទីស្ដីការគណៈរដ្ឋមន្ត្រី
«ដើម្បីសូមជ្រាបជាពត៌មាន»
_គ្រប់សាលាខេត្ត_ក្រុង
«ដើម្បីជូនជ្រាបជាពត៌មាន»
_គ្រប់អង្គភាពនៃទីស្ដីការក្រសួងអយក
«ដើម្បីជាពត៌មាន»
_មន្ទីរអយក គ្រប់ខេត្ត_ក្រុង
«ដើម្បីអនុវត្ត»
- កាលប្បវត្តិ
- ឯកសារ-ឆា. មចទ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា

លេខ ១១៥ អយក.ប្រក

# ប្រ ក ា ស

ស្តីពីការពង្រីក និងប្តូរឈ្មោះអនុវិទ្យាល័យ

« កំពង់ឈើទាល » ទៅជាវិទ្យាល័យ « ប្រាសាទសំបូរ »

ស្ថិតនៅក្នុងឃុំសំបូរ ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា**

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១១៩៨_៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស_៩៤ ចុះថ្ងៃទី ២០ កក្កដា ១៩៩៤ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស_រកម ០១៩៦_០១ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំយុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យ លេខ នស_រកត ០៧៩៦_៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំនេះទូទៅ ១២ឆ្នាំ
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ_បក ចុះថ្ងៃទី ២៣ មីនា ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទមចុះថ្ងៃទី ០២ មេសា ១៩៨៣ ស្តីពីការបើកសាលារៀនមធ្យមសិក្សាកំរិត១_កំរិត២
- យោងលិខិតស្នើសុំរបស់ការិយាល័យអប់រំ យុវជន និងកីឡាស្រុកប្រាសាទសំបូរ លេខ ៩១១ អយក.បស ចុះថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០០៣ ដោយមានយោបល់ឯកភាពពីមន្ទីរអប់រំ យុវជន និងកីឡា និងអភិបាលខេត្តកំពង់ធំ
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ

## ស ំ រ េ ច

ប្រការ ១ : អនុញ្ញាតអោយពង្រីក និងប្តូរឈ្មោះអនុវិទ្យាល័យ « កំពង់ឈើទាល » បច្ចុប្បន្ន ទៅជាវិទ្យាប៉េយ « ប្រាសាទសំបូរ » ស្ថិតនៅក្នុងឃុំសំបូរ ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ប្រការ ២ : វិទ្យាល័យនេះត្រូវដឹកនាំដោយនាយកម្មយរូប និង នាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗមួយចំនួនទៀតតាមអង្គការលេខនៃវិទ្យាល័យ ។

ប្រការ ៣ : នាយក_នាយករងនៃវិទ្យាល័យមានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍របស់រដ្ឋ ។

ប្រការ ៤ : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ៥ : អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានផែនការ នាយកដ្ឋានហិរញ្ញវត្ថុក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ធំ និងនាយកវិទ្យាល័យសាមីមានភារកិច្ចរៀងៗ ខ្លួនអនុវត្តប្រកាសនេះ ។

ភ្នំពេញ , ថ្ងៃទី ២៤ ខែ ១២ ឆ្នាំ ២០០៤

ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

រដ្ឋលេខាធិការ

អ៊ឹម សិទ្ធី

<u>កន្លែងទទួល</u>

- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ " ដើម្បីជ្រាបជាពតិមាន"
- សាលាខេត្តកំពង់ធំ "ដើម្បីជាពតិមាន"
- ដូចប្រការ ៥
- កាលប្បវត្តិ_ឯកសារ ឆ.មចទ

C:\New school\Increase 2.doc

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងអប់រំ យុវជន និង កីឡា

លេខ ១៣១ អយក.ប្រក

# ប្រ ក ា ស

ស្តីពីការបើកអនុវិទ្យាល័យ ប យ៉ាខា

ស្ថិតនៅក្នុងសង្កាត់ប យ៉ាខា ខណ្ឌប៉ៃលិន ក្រុងប៉ៃលិន

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១១៩៨_៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស_៩៤ ចុះថ្ងៃទី ២០ កក្កដា ១៩៩៤ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស_រកម ០១៩៦_០១ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំយុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យ លេខ នស_រកត ០៧៩៦_៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំនេះទូទៅ ១២ឆ្នាំ
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ_បក ចុះថ្ងៃទី ២៣ មីនា ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទមចុះថ្ងៃទី ០២ មេសា ១៩៨៣ ស្តីពីការបើកសាលារៀនមធ្យមសិក្សាកំរិត១_កំរិត២
- យោងលិខិតស្នើសុំរបស់សហគមន៍សង្កាត់បរយ៉ាខា ខណ្ឌប៉ៃលិន លេខ ០០១_០៤ អនុ.បយខ ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០៤ ដោយមានយោបល់ឯកភាពពីមន្ទីរអប់រំ យុវជន និងកីឡា និងអភិបាលក្រុងប៉ៃលិន
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ

## ស ំ រ េ ច

**ប្រការ ១ :** អនុញ្ញាតអោយបើកអនុវិទ្យាល័យដែលមានឈ្មោះថា : អនុវិទ្យាល័យ « ប យ៉ាខា » ស្ថិតនៅក្នុងសង្កាត់បរយ៉ាខា ខណ្ឌប៉ៃលិន ក្រុងប៉ៃលិន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ប្រការ ២ :** អនុវិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗ មួយចំនួនទៀតតាមអង្គការលេខ នៃអនុវិទ្យាល័យ ។

**ប្រការ ៣ :** នាយក_នាយករងនៃអនុវិទ្យាល័យមានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍របស់រដ្ឋ ។

**ប្រការ ៤ :** អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានផែនការ នាយកដ្ឋានហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡាក្រុងប៉ៃលិន និងនាយកអនុវិទ្យាល័យសាមីមានភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះ ។

ភ្នំពេញ , ថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០០៤

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

រដ្ឋលេខាធិការ

**អ៊ឹម សិទ្ធី**

<u>កន្លែងទទួល :</u>

- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ " ដើម្បីជ្រាបជាពត៌មាន"
- សាលាក្រុងប៉ៃលិន" ដើម្បីជាពត៌មាន"
- ដូចប្រការ ៤
- កាលប្បវត្តិ_ឯកសារ ធ.មចទ

C:\New school\K-kong2.doc

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា
លេខ ១៣៤ អយក.ប្រក

# ប្រកាស

ស្តីពីការបើកអនុវិទ្យាល័យ ពងទឹក
ស្ថិតនៅក្នុងសង្កាត់ពងទឹក ខណ្ឌដំណាក់ចង្អើរ ក្រុងកែប

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១១៩៨_៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស_៩៤ ចុះថ្ងៃទី ២០ កក្កដា ១៩៩៤ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស_រកម ០១៩៦_០១ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំយុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យ លេខ នស_រកត ០៧៩៦_៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំនេះទូទៅ ១២ឆ្នាំ
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ_បក ចុះថ្ងៃទី ២៣ មិនា ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទមចុះថ្ងៃទី ០២ មេសា ១៩៨៣ ស្តីពីការបើកសាលារៀនមធ្យមសិក្សាភូមិ១_ភូមិ២
- យោងលិខិតស្នើសុំរបស់មន្ទីរអប់រំ យុវជន និងកីឡា លេខ ០១១ អយក.ក្រក ចុះថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០០៤ ដោយមានយោបល់ឯកភាពពីអភិបាលក្រុងកែប
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ

## សម្រេច

ប្រការ ១ : អនុញ្ញាតអោយបើកអនុវិទ្យាល័យដែលមានឈ្មោះថា : អនុវិទ្យាល័យ « ពងទឹក » ស្ថិតនៅក្នុងសង្កាត់ពងទឹក ខណ្ឌដំណាក់ចង្អើរ ក្រុងកែប ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ប្រការ ២ : អនុវិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗ មួយចំនួនទៀតតាមអង្គការលេខ នៃអនុវិទ្យាល័យ ។

ប្រការ ៣ : នាយក_នាយករងនៃអនុវិទ្យាល័យមានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍របស់រដ្ឋ ។

ប្រការ ៤ : អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានផែនការ នាយកដ្ឋានហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡាក្រុងកែប និងនាយកអនុវិទ្យាល័យសាមីមានភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះ ។

ភ្នំពេញ , ថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០០៤
រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា
រដ្ឋលេខាធិការ
អ៊ឹម សេធី

កន្លែងទទួល :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ "ដើម្បីជ្រាបជាពតិមាន"
- សាលាក្រុងកែប "ដើម្បីជាពតិមាន"
- ដូចប្រការ ៤
- កាលប្បវត្តិ_ឯកសារ នា.មចទ

C:\New school\K-kong2.doc

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា
លេខ ១៧៣ អយក.ប្រក

# ប្រកាស

ស្តីពីការបើកអនុវិទ្យាល័យ សំបួរ
ស្ថិតនៅក្នុងឃុំសំបួរ ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១១៩៨_៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស_៩៤ ចុះថ្ងៃទី ២០ កក្កដា ១៩៩៤ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស_រកម ០១៩៦_០១ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំយុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យ លេខ នស_រកត ០៧៩៦_៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំនេះទូទៅ ១២ឆ្នាំ
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ_បក ចុះថ្ងៃទី ២៣ មិនា ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទមចុះថ្ងៃទី ០២ មេសា ១៩៨៣ ស្តីពីការបើកសាលារៀនមធ្យមសិក្សាកំរិត១_កំរិត២
- យោងលិខិតស្នើសុំរបស់សហគមន៍ឃុំសំបួរ ស្រុកមង្គលបូរី លេខ ២៥ ស_ប ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០០៣ ដោយមានយោបល់ឯកភាពពីមន្ទីរអប់រំ យុវជន និងកីឡា និងអភិបាលខេត្តបន្ទាយមានជ័យ
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ

## សំរេច

**ប្រការ ១ :** អនុញ្ញាតអោយបើកអនុវិទ្យាល័យដែលមានឈ្មោះថា : អនុវិទ្យាល័យ « សំបួរ » ស្ថិតនៅក្នុងឃុំសំបួរ ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

**ប្រការ ២ :** អនុវិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗ មួយចំនួនទៀតតាមអង្គការលេខ នៃអនុវិទ្យាល័យ ។

**ប្រការ ៣ :** នាយក_នាយករងនៃអនុវិទ្យាល័យមានសិទ្ធិទទួលប្រាក់បំណាច់ការកិច្ចតាមគោលការណ៍របស់រដ្ឋ ។

**ប្រការ ៤ :** អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានផែនការ នាយកដ្ឋានហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡាខេត្តបន្ទាយមានជ័យ និងនាយកអនុវិទ្យាល័យសាមី មានភារកិច្ចរៀងៗ ខ្លួនអនុវត្តប្រកាសនេះ ។

ភ្នំពេញ , ថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០០៤
ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា
រដ្ឋលេខាធិការ

អ៊ឹម សិទ្ធី

<u>កន្លែងទទួល</u> :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
  " ដើម្បីជ្រាបជាពតិមាន "
- សាលាខេត្តបន្ទាយមានជ័យ " ដើម្បីជាពតិមាន "
- ដូចប្រការ ៤
- កាលប្បវត្តិ_ឯកសារ ឆា.មចទ

C:\New school\K-kong2.doc

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

ភ្នំពេញ, ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០០៤

លេខ:......២១២.........អយក.មគទ

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

## ជំរាបមក

## លោក លោកស្រី ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្ត-ក្រុង

**កម្មវត្ថុ** : ការប្រើប្រាស់សាច់ប្រាក់សំរាប់រៀបចំប្រលងឆមាសទី ១

**យោង** : គោលការណ៍ណែនាំលេខ ១៩៣១ អយក.មចទ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០០៣ ស្តីពីការអនុវត្តកម្មវិធីសកម្មភាពជាអាទិភាព ឆ្នាំ ២០០៣ សំរាប់ការអប់រំនៅមធ្យមសិក្សា ។

- ផែនការសកម្មភាព និងការបែងចែកថវិកា កម្មវិធីសកម្មភាពជាអាទិភាពឆ្នាំ ២០០៣ របស់អង្គភាពគ្រប់គ្រងថវិកានាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ ។

ដោយនៅវង្វង់ខែកុម្ភៈ ឆ្នាំ ២០០៤នេះ គ្រប់គ្រឹះស្ថានមធ្យមសិក្សាចំនេះទូទៅ ត្រូវរៀបចំប្រលងឆមាសទី១ ឆ្នាំសិក្សា ២០០៣-២០០៤ ក្រសួងអប់រំ យុវជន និងកីឡាសូមណែនាំអនុវត្តដូចតទៅ ÷

១. សាច់ប្រាក់ដែលត្រូវយកមករៀបចំវិញ្ញាសាប្រលងឆមាស ពីថ្នាក់ទី ៧ ដល់ទី ១១ គឺត្រូវយកសាច់ប្រាក់ PAP ៣ ឆ្នាំ ២០០៣ ។ ចំពោះ គ្រប់គ្រឹះស្ថានមធ្យមសិក្សាចំនេះទូទៅត្រូវគ្រោងសាច់ប្រាក់ដែលត្រូវប្រើសំរាប់ប្រលងឆមាសទី១ នេះដោយគិតយ៉ាងច្រើនត្រឹម ១៣០០រ សំរាប់សិស្សម្នាក់ រឺ ១៣% នៃសាច់ប្រាក់សរុបដែលនឹងត្រូវទទួលបានសំរាប់ PAP ៣ ឆ្នាំ ២០០៣ ។

២. សំរាប់ PAP ៣ ឆ្នាំ ២០០៣ ត្រូវគ្រោងចំនាយតាមគោលការណ៍ថ្មីជាក់ស្តែង គឺ ៣២% យ៉ាងតិច សំរាប់សំភារៈមូលដ្ឋាន ២៦% យ៉ាងច្រើនសំរាប់កែលំអបរិស្ថាន ២២% យ៉ាងច្រើនសំរាប់សកម្មភាពកីឡា សិល្បៈ រោងជាង កសិកម្ម គេហវិទ្យា ១៣% យ៉ាងច្រើនសំរាប់រៀបចំវិញ្ញាសាប្រលងឆមាសទី១ ឆ្នាំសិក្សា ២០០៣-២០០៤ និង ៧% យ៉ាងច្រើនសំរាប់ចំណាយផ្សេងៗឥតគ្រោងទុក ។

សូមលោក លោកស្រី ប្រធានមន្ទីរផ្សព្វផ្សាយគោលការណ៍អនុវត្តជាក់ស្តែងសំរាប់ PAP ៣ ឆ្នាំ ២០០៣ នេះ អោយបានជ្រួតជ្រាបដល់គ្រឹះស្ថានមធ្យមសិក្សាចំនេះទូទៅក្រោមឱវាទ ដើម្បីគ្រោងសាច់ប្រាក់សំរាប់តំរូវការប្រលងឆមាសទី១ បានគ្រប់គ្រាន់ និងទាន់ពេលវេលា ។

ក្រសួងសង្ឃឹមលើស្មារតីយកចិត្តទុកដាក់របស់លោក លោកស្រី ប្រធានមន្ទីរក្នុងការធ្វើអោយដំនើរការប្រលងឆមាសទី១ ឆ្នាំសិក្សា ២០០៣-២០០៤ នៅតាមគ្រឹះស្ថានមធ្យមសិក្សាចំនេះទូទៅប្រព្រឹត្តទៅដោយភាពរលូន និងមានប្រសិទ្ធភាពខ្ពស់ ។

ជ. រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

រដ្ឋលេខាធិការ

អ៊ឹម សិទ្ធី

<u>ចំលងជូន</u>

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប"
- អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងអ.យ.ក
  "ដើម្បីមុខការ"
- កាលប្បវត្តិ-ឯកសារ នា.មចទ

3

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

ភ្នំពេញ, ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០០៤

**លេខ:**......293.........**អយក.**ម៩

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

## ជំរាបមក

## លោក លោកស្រី ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្ត-ក្រុង

**កម្មវត្ថុ** : ការរៀបចំធ្វើសំនួរសរសេរដើម្បីដាក់ពិន្ទុប្រចាំខែ

**យោង** : - លិខិតលេខ ២៧៥៥ អយក.ហវ ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០០២ ស្តីពីការយកវិភាគទាន រឺការប្រមូលប្រាក់គ្រប់រូបភាព រឺការសុំសំភារៈផ្សេងៗពីសិស្ស មាតាបិតាសិស្ស សំរាប់ឆ្នាំសិក្សា ២០០២-២០០៣ នៅតាមសាលាបឋមសិក្សា អនុវិទ្យាល័យ និងវិទ្យាល័យ ។

- សេចក្តីណែនាំលេខ ៥៨៤ អយក.សណន ចុះថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០០៣ ស្តីពីវិធានការទប់ស្កាត់បាតុភាពអវិជ្ជមាននានានៅតាមគ្រឹះស្ថានមធ្យមសិក្សាសារធារណៈ ។

រយៈកាលកន្លងមកនៅតាមគ្រឹះស្ថានមធ្យមសិក្សាខ្លះ នៅតែកើតមានបាតុភាពឆ្លៀតយកលុយសិស្សតាមរូបភាពលក់មេរៀន រឺសំនួរត្រួតពិនិត្យប្រចាំខែនៅឡើយ ដែលជាប្រការផ្ទុយនឹងគោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល ។

ចំពោះករណីនេះ ក្រសួងអប់រំ យុវជន និងកីឡាសូមណែនាំដូចខាងក្រោម ÷

១. ហាមដាច់ខាត មិនអោយថតចំលងមេរៀនលក់អោយសិស្ស ទោះជាមេរៀនសង្ខេបក្តី ព្រោះសិស្សមានសៀវភៅសិក្សាគោលហើយ ។

២. ចំពោះការធ្វើសំនួរត្រួតពិនិត្យ គប្បីអោយសិស្សធ្វើនៅលើក្រដាសសៀវភៅរបស់ខ្លួនដោយ ÷

-គ្រូចំលងសំនួរទំរង់បិទនៅលើក្តារខៀនដែលមានវាំងននបិទ អោយសិស្សឆ្លើយដោយគ្រាន់តែសរសេរលើក្រដាសសៀវភៅនូវចំនងជើងចំលើយណាដែលសិស្សយល់ថាត្រឹមត្រូវ ។ ក្នុងករណីនេះបន្ទប់រៀននីមួយៗត្រូវមានវាំងននបិទក្តារខៀន ដោយចំណាយថវិកា PAP ។

-គ្រូចំលងសំនួរទំរង់បិទលើផ្ទាំងក្រដាសសខ្នាតធំ (Poster )យកមកបិទនៅលើក្តារខៀន ហើយអោយសិស្សសរសេរចំនងជើងចំលើយណាដែលខ្លួនយល់ថាត្រឹមត្រូវលើសន្លឹកកិច្ចការរបស់ខ្លួន ។ ករណីនេះ គ្រឹះស្ថាន

មធ្យមសិក្សាត្រូវផ្តល់ផ្ទាំងក្រដាសសធំដល់គ្រូ ដោយប្រើថវិកា PAP ។

ចំពោះសំនួរទំរង់បើក គ្រូហៅសំនួរ រឺប្រធានបទអោយសិស្សចំលង និងឆ្លើយលើសន្លឹកកិច្ចការរបស់ខ្លួន ។

ក្រសួងសង្ឃឹមលើមនសិការ វិជ្ជាជីវៈ របស់លោក លោកស្រី ជាអ្នកគ្រប់គ្រង និងជាអ្នកបង្រៀនក្នុងការអនុវត្តតាមការណែនាំនេះ ដើម្បីរក្សាតំលៃជាអ្នកអប់រំផង និងរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់សិស្ស មាតាបិតាសិស្សផង ។

សូមលោក លោកស្រី ប្រធានមន្ទីរយកចិត្តទុកដាក់តាមដានត្រួតពិនិត្យ និងកាត់បន្ថយ ឈានលប់បំបាត់បាតុភាពអវិជ្ជមាននេះអោយបានរស់ជាស្ថាពរ ។

ជ. រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

រដ្ឋលេខាធិការ

**អ៊ឹម សិទ្ធី**

<u>ចំលងជូន</u>

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប"
- អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងអ.យ.ក
  "ដើម្បីមុខការ"
- កាលប្បវត្តិ-ឯកសារ ទា.អចទ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងយុត្តិធម៌

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

លេខ : ០១/ប្រក. ០៣

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០០៣

# ប្រកាសអន្តរក្រសួង

## ស្តីពី

## ការកំណត់ភារកិច្ចរបស់តុលាការ និងគណៈកម្មការសុរិយោដី ពាក់ព័ន្ធនឹងរឿងវិវាទដីធ្លី

### រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

### រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងយុត្តិធម៌

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល

-បានឃើញអនុក្រឹត្យលេខ ៤៧ អនក្រ/បក. ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី

-តាមការចាំបាច់របស់ក្រសួងយុត្តិធម៌ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

### សំរេច

**ប្រការ១** : វិវាទដីធ្លីទាំងឡាយត្រូវបានបែងចែកទៅតាមសមត្ថកិច្ចនីមួយៗដូចតទៅ ÷

-វិវាទដីធ្លីដែលបានចុះបញ្ជីសុរិយោដីរួចហើយ គឺដីធ្លីដែលមានប័ណ្ណសំគាល់សិទ្ធិគ្រប់ប្រភេទចេញដោយរដ្ឋបាលសុរិយោដី ត្រូវស្ថិតក្នុងសមត្ថកិច្ចរបស់តុលាការ

-វិវាទដីធ្លីដែលមិនទាន់បានចុះបញ្ជីសុរិយោដី គឺដីធ្លីដែលពុំទាន់មានប័ណ្ណសំគាល់សិទ្ធិគ្រប់ប្រភេទចេញដោយរដ្ឋបាលសុរិយោដីត្រូវស្ថិតក្នុងសមត្ថកិច្ចរបស់គណៈកម្មការសុរិយោដី ។

**ប្រការ២ :** តុលាការគ្រប់ខេត្ត ក្រុង ត្រូវបញ្ឈប់ការទទួលបណ្តឹងវិវាទដីធ្លីមិនទាន់ចុះបញ្ជីសុរិយោដីដែលជាសមត្ថកិច្ចរបស់គណៈកម្មការសុរិយោដីចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ប្រការ៣ :** បណ្តឹងវិវាទដីធ្លីមិនទាន់ចុះបញ្ជីសុរិយោដីដែលជាសមត្ថកិច្ចរបស់គណៈកម្មការសុរិយោដី ហើយត្រូវបានតុលាការគ្រប់ថ្នាក់ទទួល និងកំពុងចាត់ការមុនថ្ងៃចេញប្រកាសនេះ តុលាការត្រូវចាត់ការបន្តរហូតចប់សព្វគ្រប់ជាស្ថាពរ ។

**ប្រការ៤ :** វិវាទអំពីកិច្ចសន្យាពាក់ព័ន្ធនឹងដីធ្លីមិនទាន់ចុះបញ្ជីសុរិយោដីដូចជា វិវាទអំពីការបែងចែកមរតក និងវិវាទអំពីកិច្ចសន្យាទិញ លក់ ជួល បញ្ចាំ ជាដើម ជាសមត្ថកិច្ចរបស់តុលាការ ។

**ប្រការ៥ :** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ៦ :** តុលាការគ្រប់ថ្នាក់ អគ្គាធិការដ្ឋាន នាយកដ្ឋានពាក់ព័ន្ធក្រោមឱវាទក្រសួងយុត្តិធម៌ អគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្ត ក្រុង ក្រោមឱវាទក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងគណៈកម្មការសុរិយោដីគ្រប់ថ្នាក់មានភារកិច្ចទទួលបន្ទុកអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រី**
**ក្រសួងយុត្តិធម៌**

អាង វង្សវឌ្ឍនា

**រដ្ឋមន្ត្រី**
**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

អ៊ឹម ឈុនលឹម

**កន្លែងទទួល**

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ទីស្តីការគណៈរដ្ឋមន្ត្រី

-គ្រប់ក្រសួង ស្ថាប័ន

-គ្រប់សាលាខេត្ត ក្រុង

" ដើម្បីជូនជ្រាប "

-ដូចប្រការ ៦ " ដើម្បីអនុវត្ត "

-ឯកសារ-កាលប្បវត្តិ